**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ...១០៣៨......ក.ស.ភ.

ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែតុលា គ.ស.២០១៧

# សេចក្តីប្រកាសព័ត៌មាន

**កំពង់ផែស្វយ័តភ្នំពេញ** (**ក. ស. ភ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក" របស់ ក. ស. ភ. ទាំងអស់មេត្តាជ្រាបថា៖ យោងតាមកិច្ចពិភាក្សាលើលទ្ធផលនៃការប៉ាន់ស្មានប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៧ របស់ ក. ស. ភ. ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៧ អាណត្តិទី៦ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាលរបស់ ក. ស. ភ. អាចនឹងពិចារណាបង្កើនលទ្ធភាពបែងចែកភាគលាភសំរាប់ឆ្នាំ២០១៧ ជូនភាគហ៊ុនិកប្រភេទ "ក" របស់ ក. ស. ភ. ក្នុងចំនួន ៦% នៃថ្លៃ IPO បើលទ្ធផលអាជីវកម្ម/ហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០១៧ នេះ សម្រេចបានតាមការប៉ាន់ស្មានទុកនាបំណាច់ឆ្នាំ២០១៧។

ការសម្រេចជាផ្លូវការលើការបែងចែកភាគលាភឆ្នាំ២០១៧ នឹងធ្វើឡើងក្រោយពីការអនុម័តដោយក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៧ របស់ ក. ស. ភ. ដែលធ្វើសវនកម្មដោយសវនករឯករាជ្យ (KPMG) ក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០១៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកប្រភេទ "ក" និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh